# រឿង ចាបស្រុកនិងចាបព្រៃ

---

កាលពីព្រេងនាយ មានចាបស្រុកនិងចាបព្រៃ ដើររកស៊ីដោយពួកជារាល់ថ្ងៃ ។ ខាងចាបស្រុកមានមេបាប្រដៅថា «បើរកស៊ីកុំជជែកឈ្លោះគ្នា ឲ្យព្ញមាត់គឹកកងឡើយ ឲ្យប្រយ័ត្នខ្លួនបើព្រានវាវាយលប់ត្រូវឲ្យបបួលគ្នាខំហើរទូលលប់ឲ្យរបើក ដើម្បីនឹងឲ្យរួចរស់ជីវិត ។ ពួកចាបស្រុក ក៏ធ្វើតាមដំបូន្មានមេបាប្រដៅ តែងដើររកស៊ី មិនសូវហ៊ានមាត់ឲ្យព្ញជាគឹកកងទេ ជួនកាលបើព្រានវាយលប់ត្រូវ ក៏បបួលគ្នាខំហើរទូលលប់ព្រាន បានរួចជីវិតតែរៀងៗមក ។ មានកាលថ្ងៃ១ពួកចាបព្រៃ និងចាបស្រុកហើរចេញទៅរកស៊ី ជួបប្រទះហ្វូងគ្នា នៅដើមត្រែង១ គុម្ព ។ ពួកចាបព្រៃទំនៅខាងក្រោម ពួកចាបស្រុកទំនៅខាងលើ ក៏បាក់មែកត្រែងពីលើមកត្រូវក្បាលចាបព្រៃៗ និយាយប្រកាន់ទៅចាបស្រុកថា «ហេតុអីក៏កាច់មែកត្រែងទម្លាក់មកឲ្យត្រូវក្បាលពួកយើង?» ។ ចាបស្រុកក៏បានប្រាប់ទៅចាបព្រៃវិញថា «យើងមិនបានកាត់មែកត្រែងឲ្យបាក់ត្រូវអ្នកឯងទេ គឺមែកត្រែងវាបាក់ឯងធ្លាក់មកទេតើ» ។ ពួកចាបព្រៃជាពួកឥតកាន់ដំបូន្មាន មិនពិចារណាឲ្យឃើញខុសត្រូវ ក៏បបួលគ្នាបង្កហេតុ បង្កើតជាជម្លោះនឹងពួកចាបស្រុក ព្ញមាត់ជាគឹកកងរំពងឡើង ។ ពួកព្រានព្ញមាត់ចាបនៅគុម្ពត្រែងនោះច្រើន ក៏យកលប់ទៅវាយត្រូវទាំងអស់គ្នា ។ ចាបទាំងពីរពួកនេះ បានត្រូវលប់ហើយ ក៏នៅតែជាប់ឈ្លោះគ្នាទៀត ។ ចាបស្រុកពោលទៅចាបព្រៃថា «បើពួកឯងគ្រាន់បើ ហេតុម្តេចក៏មិនបម្រះឲ្យរួចពីលប់ទៅ» ។ ចាបព្រៃក៏ពោលមករកចាបស្រុកវិញថា «បើពួកឯងគ្រាន់បើ ហេតុម្តេចក៏មិនបម្រះឲ្យរួចពីលប់នេះទៅ» បានតែពាក្យបញ្ជូនគ្នាទៅវិញទៅមក មិនគិតបម្រះឲ្យរួចជីវិតសោះ» ។ កំពុងតែឈ្លោះគ្នា ស្រាប់តែព្រានក្រសោបឡើង ចាប់បានចាបទាំងអស់ ក៏ពិឃាដក្ស័យអស់ ។ នេះហើយចាបស្រុក ជាពួកចាបល្អ តែខកខ្លួនមករកស៊ីជួបចូលនឹងហ្វូងចាបព្រៃ ជាពួកចាបប្រព្រឹត្តអាក្រក់ ក៏មានរឿងឈ្លោះគ្នាទាល់តែព្រានវាយលប់ត្រូវស្លាប់ទាំងអស់គ្នា ។

**ចោទគេដោយស្មាន ត្រឡប់បានក្តីទុក្ខ**